Candidate for Prime Minister of Cambodia
DARAN KRAVANH
ក្រវាញ ដារ៉ាន
Together, we will… end poverty, create hope.
KHMER ANTI-POVERTY PARTY
គណបក្សខ្មែរឈប់ក្រ

Candidate for Prime Minister of Cambodia
DARAN KRAVANH
ក្រវាញ ដារ៉ាន
Together, we will… end poverty, create hope.
KHMER ANTI-POVERTY PARTY
គណបក្សខ្មែរឈប់ក្រ

Candidate for Prime Minister of Cambodia
DARAN KRAVANH
ក្រវាញ ដារ៉ាន
Together, we will… end poverty, create hope.
KHMER ANTI-POVERTY PARTY
គណបក្សខ្មែរឈប់ក្រ

***តើគណបក្សខ្មែរឈប់ក្រ មានវិធានការជួយបង្កើនគុណភាពផ្នែកការសិក្សាអប់រំដែរឬទេ?***

***ចម្លើយ៖*** ស្របនឹងឧត្តមគតិគណបក្សខ្មែរឈប់ក្រ ក្នុងមនសិការលើកស្ទួយចំណេះដឹង និងអំណាចរបស់ពលរដ្ឋ យើងមាន គម្រោងកែទម្រង់ស្ថាប័នអប់រំដូចតទៅ៖

*១.* ផ្តល់ការសិក្សាអប់រំដោយឥតគិតថ្លៃ ពីថ្នាក់មត្តេយ្យដល់ចប់ថ្នាក់ទី១២។

*២.* ផ្តល់អាហារដល់សិស្សពីរពេលក្នុងមួយថ្ងៃ និងយានជំនិះដល់សិស្សានុសិស្សគ្រប់រូបដែលរស់នៅឆ្ងាយពីសាលា ចម្ងាយលើសពី១,៦គីឡូម៉ែត្រឡើងទៅ។

*៣.* បង្កើនប្រាក់បៀវត្សរ៍គ្រូបង្រៀន និងមានកម្មវិធីតម្លើងប្រាក់ខែតាមលទ្ធភាពនិងគុណសម្បត្តិគ្រូ។

*៤.* ផ្តល់អាហារូបករណ៍ដល់សិស្សានុសិស្សដែលបានទទួលចំណាត់ថ្នាក់ខ្ពស់ សម្រាប់ការសិក្សាបន្តទៅមហាវិទ្យាល័យក្នុងប្រទេស ក៏ដូចជាទៅក្រៅប្រទេសដែរ។ គណៈកម្មការត្រួតពិនិត្យត្រូវទទួលបន្ទុកក្នុងការធានាតម្លាភាពនិងយុត្តិធម៌នៃការផ្តល់ ឬបែងចែកអាហារូបករណ៍ ដើម្បីជៀសវាងអំពើពុករលួយ និងបក្សពួកនិយម។

*៥.* តម្កើងគុណភាពសិក្សាអប់រំឲ្យបានដល់ខ្នាតអន្តរជាតិ ដោយទទួលយកកំរិត និងកម្មវិធីសិក្សារបស់សហរដ្ឋអាមេរិក។

*៦.* ចូលរួមក្នុងកម្មវិធីប្តូរសិស្សអន្តរជាតិ (International Student Exchange) ជាមួយ បណ្តាប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យពិសេសគឺពីអាឡប្រទេស។

*៧.* បង្កើតកម្មវិធីវិញ្ញាបនប័ត្រជាមួយសហរដ្ឋអាមេរិក ដើម្បីធានាសុពលភាពដល់គុណភាពនៃកំរិតវិជ្ជានិស្សិតខ្មែរ (Certification Program with USA to Validate Qualification of Cambodian College Graduates) ។

*៨.* បង្កើតកម្មវិធីហាត់រៀនធ្វើការងារ [ អន្តេវាសិក ] (Internship) ជាមួយសហរដ្ឋអាមេរិក ដូចជាគិលានុបដ្ឋាក និងគិលានុបដ្ឋាយិកា (Nurses) មកទទួលការហ្វឹកហ្វឺនផ្ទាល់ពីសហរដ្ឋអាមេរិក ដើម្បីឲ្យស្គាល់ពីគុណភាពសេវាកម្ម និងតម្លៃជីវិតនៃអ្នកជម្ងឺ។

*៩.* បង្កើននិងជម្រុញការហ្វឹកហ្វឺនគរុកោសល្យ និងក្រមសីលធម៌ (Teacher ’s Certification and Ethical Guidelines) ដល់គ្រូបង្រៀនគ្រប់ស្រទាប់ជាន់ថ្នាក់ ដើម្បីនឹងអាចធានាគុណភាពខ្ពស់នៃការផ្តល់វិជ្ជាដល់កូនខ្មែរ។

*១០.* បង្កើតសេវាកម្មផ្នែកសង្គមកិច្ចដើម្បីជួយដោះស្រាយមាតាបិតាសិស្សនូវរាល់បញ្ហាដែលទាក់ទងទៅនឹងការសិក្សា ក៏ដូចជាការរស់នៅ និងសុខមាលភាព សព្វសារពើ។

## រូបភាពសមិទ្ធិផលនៃគណបក្សខ្មែរឈប់ក្រ

Daran Kravanh & APISA's Presidents
" The Congress of the Asian Political & International Studies Association "
Taiwan, Nov. 2011 →



The Joys After Signing The NAC's Agreement

Phnom Penh, Dec.. 2011 →







↑ Daran Kravanh During The European Parliament's Assembly Meeting, Brussels, Belgium, May 2012 ↑




KAPP's delegation at the EU's District, Brussels, Belgium, May 2012

# គណបក្សខ្មែរឈប់ក្រ

## *KHMER ANTI-POVERTY PARTY*



## ក្រវាញ ដារ៉ាន

### បេក្ខជននាយករដ្ឋមន្ត្រី

*គណបក្សខ្មែរឈប់ក្រត្រូវបានបង្កើតឡើងនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ ២០០៧ ដោយពលរដ្ឋខ្មែររស់នៅសហរដ្ឋអាមេរិកនិងនៅកម្ពុជា រួមជាមួយនិងក្រុមអ្នកគាំទ្រជាតិអាមេរិកាំង បានរួមគ្នាធ្វើពលិកម្មគ្រប់បែបយ៉ាង ក្នុងបំណងជួយឲ្យជីវិតខ្មែរបានប្រសើរឡើងវិញ។ គណបក្សនេះបានទទួលសច្ចានុម័តពីរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៧។*

WWW.KHMERANTIPOVERTYPARTY.COM

Candidate for Prime Minister of Cambodia
DARAN KRAVANH
ក្រវាញ ដារ៉ែន
Together, we will… end poverty, create hope.
Kaneer
KHMER ANTI-POVERTY PARTY
គណបក្សខ្មែរឈប់ក្រ
Candidate for Prime Minister of Cambodia
DARAN KRAVANH
ក្រវាញ ដារ៉ែន
Together, we will… end poverty, create hope.
Kaneer
KHMER ANTI-POVERTY PARTY
គណបក្សខ្មែរឈប់ក្រ

# គណបក្សខ្មែរឈប់ក្រ

**" កសាងឡើងវិញនូវភ័ព្វវាសនាដ៏ល្អប្រសើរជូនកម្ពុជា "**

គណបក្សខ្មែរឈប់ក្រយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើភាពក្រីក្រ ពីព្រោះភាពក្រីក្រនេះតែងបណ្តាលឲ្យមានទុក្ខវេទនា បំផ្លាញជីវិតមនុស្សជាតិ បំផ្លាញព្រលឹង និងសក្តានុពលរបស់មនុស្សលោក។

***និមិត្តសញ្ញារបស់គណបក្សខ្មែរឈប់ក្រ មានន័យដូចតទៅនេះ ៖***
ដើមឈើគឺជាតំណាងនៃជីវិត ។ ដើមឈើគឺជារុក្ខជាតិដែលផ្តល់នូវអាហារនិងខ្យល់អុកស៊ីហ្សែន ដែលជាគ្រឿងចាំបាច់បំផុតសម្រាប់ជីវិត។ ដើមឈើក៏ជាជម្រកដ៏សំខាន់នៃសព្វសត្វទាំងឡាយផងដែរ។ ជាមួយគ្នានិងការបណ្តុះព្រៃឈើឡើងវិញ នោះយើងនឹងអាចធ្វើឲ្យទឹកដីកម្ពុជាមានសម្រស់ដូចដើមវិញជាមិនខាន។ រីឯភ្នំវិញគឺជាតំណាងនៃស្ថេរភាពនិងភាពសម្បូណ៌រុងរឿង។

***បាវចនាដែលមានចារក្នុងនិមិត្តសញ្ញារបស់គណបក្សគឺ ៖***

*" ស្រឡាញ់ សេរីភាព យុត្តិធម៌ និង៍សុភមង្គល "*
Love ~ Liberty ~ Justice ~Happiness

# គោលនយោបាយរបស់គណបក្ស

**Khmer Anti-Poverty Party Platform**

***<u>មូលដ្ឋានគោលនយោបាយរបស់គណបក្សខ្មែរឈប់ក្រ (Vision)</u>***
គោលការណ៍កំពូលរបស់គណបក្សគឺបំបាត់ភាពក្រីក្រ និងកសាងឡើងវិញនូវភ័ព្វវាសនាដ៏ល្អប្រសើរជូនកម្ពុជា រួមទាំងនាំមកនូវជីវិតថ្លៃថ្នូរ សុវត្ថិភាព យុត្តិធម៌ សន្តិភាព សមភាព និងសិទ្ធិសេរីភាពជូនពលរដ្ឋខ្មែរគ្រប់ៗរូប។ រាល់កិច្ចការ នឹងត្រូវបានអនុវត្ត ដើម្បីនឹងអាចនាំឲ្យយើងឈានទៅដល់ទិសដៅនោះក្នុងពេលដ៏ខ្លីខាងមុខ។

***<u>គោលការណ៍ចម្បងរបស់គណបក្ស (Mission)</u>***
គណបក្សខ្មែរឈប់ក្រនឹងបំបាត់ភាពក្រីក្រ ព្រមទាំងកសាងកម្ពុជាឲ្យមានភ័ព្វវាសនាដ៏រុងរឿងឡើងវិញ រួមទាំងនាំមក នូវជីវិតថ្លៃថ្នូរ សុវត្ថិភាព យុត្តិធម៌ សន្តិភាព សមភាព និងសិទ្ធិសេរីភាព ជូន →

ពលរដ្ឋខ្មែរគ្រប់ៗរូប។

គម្រោងអនុវត្តសំខាន់ៗនៃគោលការណ៍នេះគឺ ការពារទឹកដីកម្ពុជា អភិវឌ្ឍន៍សេដ្ឋកិច្ច អភិវឌ្ឍន៍ជនបទ អភិវឌ្ឍន៍វិស័យយុវវ័យ តម្លើងគុណភាពនៃការថែរក្សាសុខភាព បង្កើនបរិមាណទឹកស្អាត និងបំបាត់អំពើពុករលួយ។

***<u>គណបក្សខ្មែរឈប់ក្រនឹង ៖</u>***

- បង្កើតការងារជូនពលរដ្ឋ — Job Development
- បំបាត់ភាពក្រីក្រ — Eliminate Poverty
- រក្សាការពារទឹកដី — Land Protection
- បណ្តុះព្រៃឈើឡើងវិញ — Reforestation, Afforestation
- បំបាត់អំពើពុករលួយ — Stop Corruption
- ផ្តល់ប្រាក់សង្គមសង្គ្រោះ — Social Security
- អភិវឌ្ឍនវិស័យយុវវ័យ — Youth Development
- តម្លើងគុណភាពនៃការអប់រំ — Education

***<u>គណបក្សខ្មែរឈប់ក្រ មានជំនឿថា ៖</u>***

- ជីវិតមនុស្សមានតម្លៃជាទីបំផុត
- សន្តិភាពនិងយុត្តិធម៌ គឺជាកត្តាចាំបាច់ក្នុងការផ្តល់នូវគុណភាពនៃជីវិត
- សម្បត្តិធម្មជាតិកម្ពុជា គឺជាកម្មសិទ្ធិរបស់ពលរដ្ឋខ្មែរទាំងអស់
- ពលរដ្ឋខ្មែរសមតែនឹងទទួលបាននូវអ្វីដែលជាតម្រូវការចាំបាច់សម្រាប់ជីវិតរបស់ខ្លួន
- ពលរដ្ឋខ្មែរជាមនុស្សល្អ មានបេះដូងបវរ ដែលសមតែនឹងទទួលបាននូវជីវិតដ៏ល្អប្រសើរ
- ច្បាប់ទម្លាប់ត្រូវតែអនុវត្ត ដើម្បីនាំមកនូវសណ្តាប់ធ្នាប់ និងភាពសមរម្យឡើងវិញ
- ពលរដ្ឋខ្មែរត្រូវមានសិទ្ធិសម្រេចជោគវាសនារបស់ខ្លួនដោយខ្លួនឯង

***<u>តើគណបក្សខ្មែរឈប់ក្រប្លែកពីគណបក្សដទៃឯទៀតដូចម្តេចខ្លះ?</u>***
***<u>ចម្លើយ៖</u>*** មេដឹកនាំគណបក្សនេះគឺលោក **ក្រវ៉ាញ ដារ៉ែន** ជាខ្មែរមួយរូបដែលស្រលាញ់យ៉ាងប្តូរផ្តាច់ចំពោះមនុស្សជាតិ។ លោកបានឆ្លងកាត់យុគសោកនាដកម្មខ្មែរក្រហមកុម្មុយនីស រួចបានភៀសខ្លួនចេញពីកម្ពុជានៅឆ្នាំ ១៩៨៤ ហើយបានចូលមកជ្រកកោននៅសហរដ្ឋ →

អាមេរិក តាំងពីឆ្នាំ ១៩៨៨ ។ ជារៀងរហូតមក លោកមានមុខការជាអ្នកបម្រើសង្គម បានធ្វើពលីកម្មក្នុងការបម្រើក្រុមយុវវ័យ ជនពិការ និងជនក្រីក្រ។

លោក **ក្រវ៉ាញ ដារ៉ែន** ជាមេដឹកនាំខ្មែរមួយរូបដែលមានប្រវត្តិជាជនមិនមានបាតដៃប្រឡាក់ឈាមឡើយ។ លោកបានបម្រើពលរដ្ឋដោយសុទ្ធចិត្ត មិននិយមទាមទារនូវអំណាច បុណ្យស័ក្តិ លាភសក្ការៈ ផ្ទាល់ខ្លួនអ្វីទាំងអស់។ ទស្សនៈ និងឧត្តមគតិរបស់លោកអាច យកជាគំរូក្នុងការជំរុញឲ្យមានភាពលូតលាស់ក្នុងភាពជាអ្នកដឹកនាំ ដើម្បីលើកតម្កើងគុណភាពជីវិតមនុស្សគ្រប់រូប។
គណបក្សខ្មែរឈប់ក្រ ប្រឹងបង្កើតនូវអ្វីមួយដ៏ថ្មី ហើយបរិសុទ្ធ ដើម្បីជូនទៅពលរដ្ឋខ្មែរ ដោយបញ្ចូលគ្នានូវឧត្តមគតិដ៏ប្រពៃបំផុតរបស់ខ្មែរអាមេរិកាំង និងគណៈដឹកនាំពិភពលោក។ មានជនជាតិអាមេរិកាំងជាច្រើននាក់បានចូលរួមផ្តល់គំនិតនិងយោបល់ក្នុងការជួយអភិវឌ្ឍន៍គម្រោងនយោបាយ ហើយបានជួយឲ្យគណបក្សនេះប្រកបដោយតម្លាភាពផងដែរ។ អស់លោកដែលជាអ្នកធ្វើពលិការដល់គណបក្សនេះ គឺជួយដោយសុទ្ធចិត្ត ពុំមានគិតពីប្រាក់កំរៃឡើយ។

***<u>តើគណបក្សខ្មែរឈប់ក្រមានវិធានការជួយដោះស្រាយបញ្ហាកង្វះការងារនៃនិស្សិតដែលបានបញ្ចប់ការសិក្សាហើយនោះដែរឬទេ?</u>***
***<u>ចម្លើយ៖</u>*** គណបក្សខ្មែរឈប់ក្រ នឹងមាន ៖
១. បង្កើតការងារនៅគ្រប់ស្ថាប័នតាំងពីអភិបាលកិច្ចពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម បច្ចេកវិជ្ជា វិទ្យាសាស្ត្រ សិល្បៈ និងវប្បធម៌ រុក្ខាប្រមាញ់ ប្រៃសណីយ៍និងទូរគមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធនិងក្រសួងការពារបរិស្ថាន។
២. ប្រើថវិកាជាតិដើម្បីបង្កើតការងារទាំងអស់គ្រប់ស្រទាប់ជាន់ថ្នាក់តាមតម្រូវការចាំបាច់។
៣. បង្កើតគណៈកម្មការត្រួតពិនិត្យនិងធានាគុណភាពគ្រប់ស្ថាប័នដែលជាកិច្ចបង្កើនការងារជូននិស្សិត ក៏ដូចជាការបង្កើនភាពស្អាតស្អំ យុត្តិធម៌ តម្លាភាពនិងតុល្យភាព គ្រប់ក្រសួងនិងស្ថាប័នជូនពលរដ្ឋ។